00207782

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

A 189/I/6

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១០)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២៤ កក្កដា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 07 / 2008
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## សាធារណៈ

## សេចក្តីសម្រេចដោយអនុលោមតាមមាត្រា ៣(១២) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះការតែងតាំងអ្នកជំនាញ

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡៅ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

00207783



A189/I/6

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក")** កត់សម្គាល់ឃើញមានឯកសារដូចខាងក្រោម ដែលភាគីដាក់ឯកសារ បានសរសេរសម្គាល់ថា "សាធារណៈ"៖

(១) បណ្តឹងឧទ្ធរណ៍ចំពោះការបដិសេធតាមការសន្មតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើ *សំណើសុំឱ្យអ្នកជំនាញចិត្តសាស្ត្រធ្វើការពិនិត្យលោក អៀង សារី ដើម្បីបញ្ជាក់សមត្ថភាពចូលរួមក្នុងការជំនុំជម្រះ* ដែលសហមេធាវីលោក អៀង សារី បានដាក់នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨។

(២) សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ចំពោះការតែងតាំងអ្នកជំនាញដើម្បីធ្វើការវាយតម្លៃសមត្ថភាពចូលរួមក្នុងការជំនុំជម្រះ ដែលសហព្រះរាជអាជ្ញាបានដាក់នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨។

២. មាត្រា ៣(១២) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអវតក[១] ចែងថា:

"ការស៊ើបសួរត្រូវធ្វើឡើងជាសម្ងាត់។ ភាគីដែលដាក់ឯកសារអាចបង្ហាញពីសំណូមពររបស់ខ្លួនដើម្បីដាក់ឯកសារនោះជាអត្ថបទ"សាធារណៈ" "សម្ងាត់" ឬ "បិទស្លាកបោះត្រា" ទៅតាមករណីសមស្រប។ មានតែសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះប៉ុណ្ណោះ ដែលមានអំណាចពិនិត្យមើលឯកសារដើម្បីកំណត់ថា តើការកំណត់ប្រភេទអត្ថបទទាំងនោះមានលក្ខណៈសមរម្យដែរឬទេ។ សេចក្តីសម្រេចណាមួយស្តីពីបញ្ហានេះរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះត្រូវមានអានុភាពអនុវត្តក្នុងអំឡុងពេលនៃសវនាការបន្តបន្ទាប់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមានអំណាច តាមគំនិតផ្តួចផ្តើម ឬ តាមពាក្យសុំរបស់ភាគី ក្នុងការកែប្រែសេចក្តីសម្រេចនោះមួយផ្នែក ឬ ទាំងមូល ក្រោយពីបានជូនដំណឹងទៅភាគី ដែលអាចទទួលឥទ្ធិពលនៃសេចក្តីសម្រេចនោះ និង ផ្តល់ឱ្យភាគីនូវសិទ្ធិចូលរួមសវនាការ។

៣. អង្គបុរេជំនុំជម្រះបានពិនិត្យមើលឯកសារនេះឡើងវិញ ដើម្បីបញ្ជាក់ថាចំណារដែលសសេរសម្គាល់ថា "សាធារណៈ" នេះធ្វើឡើងសមរម្យដែរឬទេ។

៤. អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណារថា "សាធារណៈ" នេះធ្វើឡើងមិនសមរម្យឡើយ ដោយសារឯកសារទាំងនេះមានការពិភាក្សារៀបរាប់អំពីបញ្ហាវេជ្ជសាស្ត្រ និងរួមមានព័ត៌មានស្តីពីស្ថានភាពសុខភាពរបស់លោក អៀង សារី។

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

ឯកសារទាំងនេះត្រូវចាត់ថ្នាក់ថាជាឯកសារ **"សម្ងាត់"**។

ភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C. * C.E.T.C.

**ប្រាក់ គឹមសាន**

[១] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វ០២ "ការដាក់ឯកសារនៅ អ.វ.ត.ក" ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨។